ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន

លេខ ១២៣/ស.ហ.ក អ.ជ.ប.គ.ញ
/១១

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១

# របាយការណ៍

## ស្ដីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ កក្កដា ឆ្នាំ ២០១១
## និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ សីហា ឆ្នាំ ២០១១

(០១/៧/២០១១-៣១/៧/២០១១)

ខែកក្កដាឆ្នាំ២០១១ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានខិតខំអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ២០១១នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរយៈលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ក្នុងខែកក្កដាឆ្នាំ២០១១នេះ ពួកឈ្មួញគ្រឿងញៀននៅតែបន្តធ្វើសកម្មភាពនាំគ្រឿងញៀនសំយោគប្រភេទ មេតំហ្វេតាមីនគ្រាប់(ភាគច្រើនមានស្លាកសញ្ញាWY) និងមេតំហ្វេតាមីនទឹកកក (ICE) ឆ្លងកាត់តាមបណ្តាខេត្តនៅភាគឦសានចូលមកក្នុងប្រទេស ។ ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបបានទាំងអស់នោះ យើងបានពិនិត្យឃើញមានបទល្មើសផលិតកែច្នៃគុណភាពគ្រឿងញៀនសំយោគ ចំនួន ២ ករណី និងការចរាចរគ្រឿងញៀនជាលក្ខណៈអន្តរជាតិ១ករណី ដែលធ្វើឡើងដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិមានអង្គការចាត់តាំង បានប្រើស្ត្រីជនជាតិនេប៉ាល់ ឱ្យនាំដំរកញ្ឆាពីទីក្រុងញូដេលី ប្រទេសឥណ្ឌា ឆ្លងកាត់កម្ពុជាក្នុងទិសដៅនាមទៅកាន់ប្រទេសថៃតាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ខែកក្កដាឆ្នាំ២០១១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និងណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន មានដូចខាងក្រោម :

១- បានស្នើសុំគោលការណ៍ ទៅសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រសួងមហាផ្ទៃរៀបចំនិងដឹកនាំគណៈកម្មការចម្រុះ ដើម្បីជួយដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្ត

ជាប់ព្រំដែន កម្ពុជា-ឡាវ ( គោលការណ៍នេះសម្តេច បានឯកភាពកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១) ។

២- បានបន្តការដឹកនាំនិងណែនាំក្រសួង-ស្ថាប័នពាក់ពន្ធ័ ដើម្បីរៀបចំឯកសារសម្រាប់ជនបង្គោល និងបណ្តុះបណ្តាលជនបង្គោលអំពីការងារផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងពីបញ្ហាគ្រឿងញៀន ។

៣- បានដឹកនាំក្រុមការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទៅចូលរួមក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ ២០១១ ។

៤- បានណែនាំឱ្យដំឡើងបញ្ជីទីកន្លែងដែលត្រូវរៀបចំឱ្យមានសេវាព្យាបាលនៅតាមសហគមន៍ឱ្យបានឆាប់ និងត្រូវទំនាក់ទំនងទៅអាជ្ញាធរដែនដីដែលមានការពាក់ពន្ធ័ទាំងនោះ ដើម្បីត្រៀមកិច្ចសហប្រតិបត្តិការជាមួយប្រទេសម៉ាឡេស៊ី ក្នុងការផ្លាស់ប្តូរបទពិសោធន៍លើការងារព្យាបាលនៅតាមសហគមន៍ ។

៥- បានណែនាំឱ្យពិនិត្យលទ្ធភាពនិងសមាសភាព មន្ត្រីទទួលបន្ទុកការងារព្យាបាលតាមសហគមន៍ ដើម្បីធ្វើការបណ្តុះបណ្តាល ឬទស្សនកិច្ចសិក្សានៅប្រទេសម៉ាឡេស៊ី លើការងារព្យាបាលតាមសហគមន៍ ដោយជ្រើសរើសសមាសភាពមន្ត្រី មកពីរាជធានី-ខេត្ត អាទិភាព ។

៦- បានណែនាំឱ្យក្រុមការងារទិន្នន័យ និងមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ខិតខំឱ្យបានសម្រេចនូវការប្រមូលទិន្នន័យមួយដែលឯកភាពគ្នា ។ ដោយឡែក ការអនុវត្តន៏កម្មវិធីប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ក្រុមការងារត្រូវរៀបចំជាតារាងឬបញ្ជី ដើម្បីឱ្យមានទិន្នន័យជាក់លាក់ ។

៧- បានណែនាំឱ្យរៀបចំលិខិតផ្លូវការ ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អេដស៍ និង ពេស្យាចារ នៃប្រទេសវៀតណាម ដើម្បីបញ្ជាក់ពីលទ្ធផលនៃការស្នើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៨- បានណែនាំឱ្យបន្តការតាមដានអំពីកាលបរិច្ឆេទ កម្មវិធី និង ខ្លឹមសារនៃដំណើរទស្សនកិច្ចទៅសាធារណរដ្ឋប្រជាមានិតចិន របស់គណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ។

៩- បានណែនាំឱ្យបន្តការតាមដាន និងជំរុញការស្វែងរកថវិកាគម្រោង សម្រាប់ការងារព្យាបាលនៅតាមសហគមន៍ដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានចុះហត្ថលេខាជាមួយ UNODC ។

១០- បានណែនាំឱ្យរៀបចំកិច្ចប្រជុំ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពន្ធនាគារ ជាមួយអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីពិភាក្សានិងដោះស្រាយបញ្ហាទណ្ឌិតនៅក្នុងពន្ធនាគារបានលួចប្រើប្រាស់គ្រឿងញៀន និងបង្កការលំបាកដល់សមត្ថកិច្ចពន្ធនាគារ និងសមត្ថកិច្ចអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន ។

១១- បានណែនាំឱ្យចូលរួមពិនិត្យ និងកែសម្រួលលើខ្លឹមសារសេចក្តីព្រាង គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា របស់ក្រសួងអប់រំយុវជន និងកីឡា ។

១២- បានណែនាំឱ្យចូលរួមប្រជុំពេញអង្គគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារគោលនយោបាយជាតិ ស្តីពីសន្តិសុខលម្ហសមុទ្រ ( ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១១) ។

១៣- បានបញ្ជូនគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅទស្សនកិច្ចនៅសាធា

រណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ថ្ងៃទី ២៥-២៨/៧/២០១១) ។

១៤- បានចាត់តំណាងទៅចូលរួមក្នុងកិច្ចប្រជុំពិភាក្សាកម្រិតជំនាញ ក្នុងការរៀបចំផែនការចំណូល-ចំណាយថវិកាឆ្នាំ ២០១២ កាលពីថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

១៥- បានណែនាំឱ្យរៀបចំកិច្ចប្រជុំកម្រិតជំនាញ ដើម្បីឆ្លងផែនការសកម្មភាពជាតិ ៥ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

១៦- បានចាត់តាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១រូប អញ្ជើញជាគណៈអធិបតីនៅក្នុងវេទិកាស្វែងយល់អំពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ។

ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ អនុវត្តសម្រេចបាននូវលទ្ធផលមួយចំនួនដូចខាងក្រោម ៖

## *១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួង-ស្ថាប័នជាសមាជិក ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានបន្តយកចិត្តទុកដាក់ក្នុងការងារលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាពសំខាន់ពីរគឺ ៖

### *១.១. សកម្មភាពអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគ្រឿងញៀន*

**ក. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការ ត្រួតពិនិត្យគ្រឿងញៀន នៅក្រុងព្រៃវែង ខេត្តព្រៃវែង នាថ្ងៃទី០៧/៧/២០១១ មានអ្នកចូលរួមចំនួន **៤០០** នាក់ និងនៅស្រុកទូកមាស ខេត្តកំពត នាថ្ងៃទី ២២/៧/២០១១ មានអ្នកចូលរួមចំនួន **៣៥០** នាក់ ។

**ខ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ** បានចាត់តំណាង (ស្នងការរងនគរបាល) ចូលរួមផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍CTN ក្រោមប្រធានបទស្តីពីការទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១) ។

### *១.២. សកម្មភាពបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យផ្សព្វផ្សាយអប់រំ*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានផ្តល់ឯកសារផ្សព្វផ្សាយអប់រំមួយចំនួនដល់អង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា សម្រាប់កម្មវិធី "ក្តីសង្ឃឹមកុមារកម្ពុជា" ដើម្បីអប់រំបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងសម្រាប់បណ្តុះបណ្តាលដល់បុគ្គលិកផ្នែកសុខភាព, អ្នកស្ម័គ្រចិត្ត, យុវជន, កុមារជំទង់, សិស្សសាលា, ប្រធានភូមិ និងប្រជាជននៅក្នុងសហគមន៍ តាមតំបន់គោលដៅ ដូចជា តំបន់ក្រីក្រជាយក្រុងភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ធំ, ខេត្តកំពង់ចាម និងខេត្តពោធិ៍សាត់ ជាពិសេស ផ្សព្វផ្សាយនៅក្នុងពេលប្រជុំបណ្តាញកម្មវិធីអេដស៍រៀងរាល់បីខែម្តង ។

សកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់ជាប្រចាំរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន មានអ្នកចូលរួមសរុប **៣.៤៣៧** នាក់ ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ខែកក្កដាឆ្នាំ២០១១ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ២.១. ការបង្ក្រាបបទល្មើសគ្រឿងញៀន

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៦២** ករណី ប្រៀបធៀប ខែមិថុនា ឆ្នាំ២០១១ ( បទល្មើសមាន **៧៩** ករណី) គឺមានការថយចុះ **២១,៥១** % ។

**-ឃាត់ខ្លួនមនុស្ស** ចំនួន **១៤៨** នាក់ ប្រៀបធៀប ខែមិថុនា ឆ្នាំ២០១១ ( ឃាត់ខ្លួនមនុស្ស **១៦៩** នាក់) គឺមានការថយចុះ **១២,៤២** % ។

**-វត្ថុតាងចាប់យក** រួមមាន :

. មេតំហ្វេតាមីនគ្រាប់ WY ២.៤២៤ គ្រាប់ . មេតំហ្វេតាមីនក្រាមម្សៅ(Ice) ៥៦២,៣១ ក្រាម

. កូកាអ៊ីន ២៩៧,៣០ ក្រាម . កញ្ឆាក្រៀម ២២២,៤០ ក្រាម . ដើកញ្ឆា ៨.១៣៨,៨០ ក្រាម

. ដើមកញ្ឆា ១១ ដើម រួមទាំងវត្ថុតាងរួមផ្សំមួយចំនួនទៀត ដូចមានរាយនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

### ២.២. ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង ចំនួន ២០៣ ករណី ស្មើនឹង ៣០១ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** មាន **៣៥ សំណាក = ១១ %** និងសំណាក **វិជ្ជមានសារធាតុញៀន** ២៦៦ សំណាក រួមមាន :

-មេតំហ្វេតាមីនក្រាមម្សៅ (Ice) ១២៣ សំណាក = ៤០ % -មេតំហ្វេតាមីនគ្រាប់WY ១០៩ សំណាក = ៣៦ %

-កេតាមីន ១៩ សំណាក = ៦ % -កញ្ឆា ០៤ សំណាក = ២ %( កញ្ឆាក្រៀម ២ សំណាក, ជ័រកញ្ឆា ២ សំណាក)

-ហេរ៉ូអ៊ីន ០៤ សំណាក = ១ % -កូកាអ៊ីន ០៣ សំណាក = ១ % -ផ្សឹដូអេហ្វេឌ្រីន ០៣ សំណាក = ១ %

### ២.៣. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

ដោយឡែក សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅក្នុងខែកក្កដាឆ្នាំ២០១១នេះ សរុបមានចំនួន ៥.០៤៥.០៨៣ គីឡូក្រាម ( មានរាយមុខសារធាតុគីមីលំអិតក្នុងតារាងឧបសម្ព័ន្ធនៅទំព័រខាងក្រោយ) ។

## ៣. ការព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

ខែកក្កដាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ជាសមាជិក រួមទាំងអង្គការជាតិ អន្តរជាតិ ដើម្បីបន្តយកចិត្តទុកដាក់លើការងារព្យាបាល មានដូចតទៅ :

### ៣.១. ការងារព្យាបាល ស្តារនីតិសម្បទា

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ**

  - អនុវត្តតាមស្មារតីប្រជុំកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការពិនិត្យពិភាក្សាលើកិច្ចដំណើរការរៀបចំសេវាថែទាំព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ បានបន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល

រៀបចំផែនការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ដើម្បីផ្តល់សេវាបន្សាបព្យាបាល និងថែទាំអ្នកញៀនគ្រឿងញៀនតាមសហគមន៍ ក្នុងនោះ ក្រសួងសុខាភិបាលនឹងធ្វើការពិនិត្យនិងពង្រឹងសមត្ថភាពឡើងវិញនូវមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ចំនួន៧៤កន្លែង ដែលមានសេវាសុខភាពផ្លូវចិត្តនិងគ្រឿងញៀនរួចហើយ ឱ្យចាប់ដំណើរការបម្រើសេវាព្យាបាលអ្នកញៀនគ្រឿងញៀន តាមផែនការនិងតម្រូវការជាក់ស្តែងប្រចាំឆ្នាំ ។

- បានរៀបចំវគ្គបណ្តុះបណ្តាលសារឡើងវិញ ចំពោះបុគ្គលិកសុខាភិបាលដែលបាននឹងកំពុងអនុវត្តកម្មវិធី ព្យាបាលដោយផ្អែកលើសហគមន៍ នៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៦ ដល់ ២៩/៧/២០១១ ដោយមានការចូលរួមធ្វើបទឧទ្ទេសនាមដោយមន្ត្រីគ្រូបង្គោល ដែលធ្លាប់បានទៅសិក្សានៅប្រទេសវៀតណាម តាមរយៈគម្រោងទ្រីតណែត ២ (Treatnet II) របស់អង្គការ UNODC ( អ្នកចូលរួម៦០នាក់) ។

➢ **ក្រសួងសុខាភិបាល** ក្នុងរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីឆ្នាំ២០១១នេះទៅ នឹងរៀបចំ :

- មន្ទីរពេទ្យបង្អែកចំនួន ៨១ (១០០%)ទូទាំងប្រទេស ឱ្យមានលទ្ធភាពអាចធ្វើការព្យាបាល បន្សាប និងថែទាំអ្នកញៀនគ្រឿងញៀន ។
- មណ្ឌលសុខភាព ( អតីតមន្ទីរពេទ្យស្រុក) ចំនួន ១០០ ឱ្យមានលទ្ធភាពអាចធ្វើការពិនិត្យ ពិគ្រោះយោបល់ និងព្យាបាលអ្នកញៀនគ្រឿងញៀន ។
- មណ្ឌលសុខភាព ចំនួន ៣០០ ឱ្យមានលទ្ធភាពអាចធ្វើការពិនិត្យ ពិគ្រោះយោបល់ និងព្យាបាលអ្នកញៀនគ្រឿងញៀន ។ **សរុបទាំងអស់ ចំនួន ៤៨១ កន្លែង** ។

ក្នុងផែនការ ៥ ឆ្នាំនេះ ជំហានដំបូង ( អាចក្នុងឆ្នាំ ២០១១) ក្រសួងសុខាភិបាលនឹងបង្កើតសេវានេះ នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកណ្តាល ខេត្តស្ទឹងត្រែង ខេត្តកំពង់ចាម ខេត្តប៉ៃលិន ខេត្តតាកែវ និង ខេត្តព្រៃវែង សរុបមានមន្ទីរពេទ្យ និង មណ្ឌលសុខភាពចំនួន ១៣៨ (រួមទាំងមន្ទីរពេទ្យនិងមណ្ឌលសុខភាព ដែលធ្លាប់មានសេវាសុខភាពផ្លូវចិត្តនិងគ្រឿងញៀនរួចហើយ) ។ ប៉ុន្តែទោះបីយ៉ាងណា ក៏គម្រោងនិងផែនការខាងលើនេះ នៅតែត្រូវការចាំបាច់នូវការគាំទ្រពីដៃគូពាក់ពន្ធ័នានា ។

### ៣.២. ***ការកាត់បន្ថយគ្រោះថ្នាក់***

➢ ***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- បានចាត់តាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមការងាររួមរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីអំពីការងារមេរោគអេដស៍/ជំងឺអេដស៍ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- បានសហការជាមួយអគ្គលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន/អេដស៍ កាលពីថ្ងៃទី២១-២២/៧/២០១១ នៅសណ្ឋាគារ តោមាស ខេត្តព្រះសីហនុ ( មានអ្នកចូលរួម ២៧ រូប) ។
- បានចាត់តាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ១ រូប តាមការអញ្ជើញរបស់គណៈកម្មាធិការអេដស៍ នៃក្រសួង

មហាផ្ទៃ ទៅចូលរួមឧទ្ទេសនាមឯកសារក្នុងវគ្គបណ្តុះបណ្តាលដល់នាយ-នាយរងនគរបាលជាតិនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ស្តីពីភាពជាដៃគូសហគមន៍ដើម្បីសុវត្ថិភាព ក្នុងការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ ការប្រើបំពានគ្រឿងញៀន និងការជួញដូរមនុស្ស និងការពារអនីតិជន កាលពីថ្ងៃទី០៤-០៨/៧/២០១១ នៅខេត្តបន្ទាយមានជ័យ ( មន្ត្រីនគរបាលចូលរួម ៣៦ នាក់ ) ។

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ១រូប ឱ្យចូលរួមក្នុងក្រុមការងារ តាមការស្នើសុំរបស់ UNODC UN AIDS WHO ដើម្បីរួមចំណែកក្នុងការផ្តល់យោបល់លើសេចក្តីព្រាងពាក់ពន្ធ័នឹងគំរូនៃនីតិវិធីប្រតិបត្តិ (SOPs) លើការងារហ៊ីវ/អេដស៍ ។
- បានជួបប្រជុំជាមួយអ្នកប្រឹក្សាឯករាជ្យសម្រាប់វាយតម្លៃការព្យាបាលដោយប្រើថ្នាំមេតាដូន កាលពីថ្ងៃទី២២ខែ កក្កដា ឆ្នាំ២០១១ តាមការស្នើសុំរបស់អង្គការ AusAID ប្រចាំនៅកម្ពុជា ។
- បានចាត់មន្ត្រីជំនាញចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍ នៅប្រទេស កម្ពុជា ឆ្នាំ២០១០ កាលពីថ្ងៃទី០៤/៧/២០១១ តាមការអញ្ជើញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគនៃក្រសួងសុខាភិបាល នៅសណ្ឋាគារសាន់វ៉េ ( អ្នកចូលរួម ១២០ នាក់ ) ។
- បានចាត់មន្ត្រី ១ រូប តាមស្នើសុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី បច្ចុប្បន្នភាពអន្តរាគមន៍ និងចំណេះដឹងវិទ្យាសាស្ត្រពីមេរោគអេដស៍និងជំងឺអេដស៍ ដែលធ្វើនៅសណ្ឋាគារ ប្រេស៊ីដង់ ខេត្តបាត់ដំបង កាលពីថ្ងៃទី១២-១៥/៧/២០១១ ( អ្នកចូលរួម ១៦ នាក់) ។

➢ ***នៅក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- បានចាត់មន្ត្រីជំនាញរបស់ខ្លួនចំនួន៣រូប និងមន្ត្រីគម្រោង HAARP ប្រចាំអគ្គលេខាធិការដ្ឋាន១រូប ទៅចូលរួម វេទិកា លើកទី៥ ស្តីពីការសម្របសម្រួលនិងទំនាក់ទំនងរបស់កម្មវិធី HAARP ពីថ្ងៃទី២៧-២៩ ខែមិថុនា ឆ្នាំ ២០១១ នៅទីក្រុងហ្លួងប្រាបាងប្រទេសឡាវដើម្បីពិភាក្សានិងបង្ហាញនូវវិធីសាស្ត្រក្នុងការសរសេររបាយការណ៍ និងវិធីសាស្ត្រទំនាក់ទំនងផ្តល់ការគាំទ្រ និងលើកកម្ពស់ដល់សកម្មភាពបណ្តាញអ្នកប្រើប្រាស់គ្រឿងញៀន អ្នកផ្ទុកមេរោគហ៊ីវ/អេដស៍, ការចូលរួមចំណែកក្នុងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រឿងញៀនក្នុងសហគមន៍ និង ការប្តេជ្ញាចិត្តរបស់គម្រោង HAARP លើការធានានិរន្តរភាពរយៈពេលវែងក្នុងសកម្មភាពនៃការអនុវត្តន៍កម្មវិធី កាត់បន្ថយគ្រោះថ្នាក់គ្រឿងញៀន និងស្វែងរកការគាំទ្រផ្នែកធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់ខ្លួន ១ រូប រួមជាមួយមន្ត្រីរបស់ក្រសួងអប់រំយុវជននិងកីឡា និង ក្រសួងសុខាភិបាល ទៅចូលរួមសិក្ខាសាលាស្តីពីការបង្ការការប្រើបំពានគ្រឿងញៀនរបស់ UNODC តំបន់ ក្រោមគម្រោង H15 កាលពីថ្ងៃទី ០៥-០៨/៧/ ២០១១ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។ គោលបំណងរបស់សិក្ខាសាលាគឺ **១.**ពិនិត្យមើលពីប្រសិទ្ធភាពនៃការអន្តរាគមន៍ដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ដែលមានក្នុងកម្មវិធីសាលារៀន ការបណ្តុះបណ្តាលជំនាញក្នុងក្រុមគ្រួសារនិងក្រុមងាយរងគ្រោះខ្ពស់, **២.**ចែករំលែកព័ត៌មានពីគំនិតផ្តួចផ្តើមបច្ចុប្បន្ននៅក្នុងប្រទេសនិងស្ថាប័ននៃប្រទេសនីមួយៗ ក្នុងការផ្តល់ការអន្តរាគមន៍ ដល់ក្រុមគ្រួសារ សាលារៀន និងក្រុមងាយរងគ្រោះខ្ពស់, **៣.** លើកឡើងពីបញ្ហាប្រឈមនិងការលំបាកនានា

ក្នុងការអនុវត្តន៍កម្មវិធីអប់រំបង្ការនៅក្នុងសាលារៀន ការបណ្តុះបណ្តាលជំនាញដល់ក្រុមគ្រួសារនិងក្រុមងាយរងគ្រោះខ្ពស់នៅក្នុងតំបន់, ៤. ពិភាក្សាស្វែងរកយុទ្ធសាស្រ្តល្អក្នុងការអនុវត្តន៍វិធានការអន្តរាគមន៍ ដោយផ្អែកលើក្រុមគ្រួសារ សាលារៀន និងក្រុមងាយរងគ្រោះខ្ពស់នៅក្នុងតំបន់ និងនៅក្នុងប្រទេសនីមួយៗ, ៥.ឯកភាពលើសកម្មភាពប្រតិបត្តិសម្រាប់គំនិតផ្តួចផ្តើមរួម ស្តីពីការបង្ការការប្រើគ្រឿងញៀនប្រភេទATS និងផលប៉ះពាល់របស់វា ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ដើម្បីលើកកម្ពស់សមត្ថភាពការងារអនុវត្តច្បាប់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានដឹកនាំនិងសហការសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងបណ្តាអង្គការជាដៃគូជាតិ និង អន្តរជាតិ តាមរយៈសកម្មភាពមានដូចតទៅ :

### ៤.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- ក្រុមការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ បានចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០១១ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- បានចាត់មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន ២ រូប ឱ្យចូលរួមក្នុងគណៈកម្មការត្រួតពិនិត្យនិងមានវិធានការដឹកនាំគ្រប់គ្រងឱ្យបានសមស្រប ចំពោះទណ្ឌិតដែលកំពុងលួចប្រើប្រាស់គ្រឿងញៀននៅមណ្ឌលកែប្រែទី១ ។
- មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន បានបញ្ចប់បេសកកម្មក្នុងការចុះក្តាប់សភាពការណ៍ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការិយាល័យទំនាក់ទំនងព្រំដែន (BLO) ទាំង ១២ ការិយាល័យនៅតាមព្រំដែន កម្ពុជា-ថៃ, កម្ពុជា-ឡាវ និង កម្ពុជា-វៀតណាម ។ តាមរយៈបេសកកម្មនេះ យើងក្តាប់បានពីសមត្ថភាពរបស់មន្ត្រីការិយាល័យ BLO មួយចំនួននៅមានកម្រិត ។ ទន្ទឹមនេះ ក៏មានសម្ភារៈមួយចំនួនខូចលែងដំណើរការបាន និងមួយចំនួនទៀតអន់គុណភាព ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីជំនាញ សរុបចំនួន ៤ រូប ដើម្បីចូលរួមក្នុងគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅបណ្តាខេត្តព្រំដែន កម្ពុជា-ឡាវ ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមសិក្ខាសាលាស្តីពីការទប់ស្កាត់បទល្មើសតាមសហគមន៍ និងការពង្រឹងនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីសុវត្ថិភាពសហគមន៍ នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី១៥/៧/២០១១ ។

### ៤.២. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រំដែន

- ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និង ខេត្តស្ទឹងត្រែង បានជួបប្រជុំជាមួយស្នងការដ្ឋាននគរបាលខេត្តចំប៉ាសាក់ ប្រទេសឡាវ នៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ នាថ្ងៃទី០៧/៧/២០១១ ដើម្បីផ្លាស់ប្តូរសភាពការណ៍ និងពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។
- ស្នងការដ្ឋាននគរបាលខេត្តកណ្តាល បានជួបប្រជុំជាមួយស្នងការដ្ឋាននគរបាលខេត្តអាងយ៉ាង(វៀតណាម) ស្តីពី

កិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនរវាងការិយាល័យ BLO ខេត្តកណ្តាល ជាមួយការិយាល័យ BLO ខេត្តអាងយ៉ាង( ប្រជុំនៅខេត្តកណ្តាល, ថ្ងៃទី១៣/៧/២០១១ មន្ត្រីចូលរួមសរុប **៤២** នាក់) ។

កិច្ចប្រជុំទាំងពីរខាងលើ សុទ្ធតែបានចុះហត្ថលេខារួមគ្នាលើកំណត់ហេតុនៃកិច្ចប្រជុំ ដោយផ្តោតសំខាន់លើការបន្តការពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

## ៥. *កិច្ចសហប្រតិបត្តិការអន្តរជាតិ*

អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្កើនកិច្ចសហប្រតិបត្តិការ ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ, បណ្តាអង្គការជាដៃគូអភិវឌ្ឍន៍នានា ដូចមានសកម្មភាពខាងក្រោម :

➢ ***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន :*

- បានជួបពិភាក្សាការងារជាមួយបណ្ឌិត Robert Ali ប្រធានផ្នែកស្រាវជ្រាវការងារព្យាបាលអ្នកញៀនគ្រឿងញៀន របស់អង្គការសុខភាពពិភពលោក កាលពីថ្ងៃទី២២/៧/២០១១ ពាក់ពន្ធ័ទៅនឹងកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនដោយប្រើប្រាស់ឱសថមេតាដូន ដែលកម្ពុជាកំពុងបារម្ភថាតើអាចធានានិរន្តរភាពនៃកម្មវិធីនេះបានកម្រិតណា ។ លោក Robert Ali បានវាយតម្លៃខ្ពស់ចំពោះកម្ពុជាក្នុងការខិតខំប្រឹងប្រែងអនុវត្តកម្មវិធីនេះ ដោយពាំនាំលទ្ធផលនៃកម្មវិធីនេះ ទៅពិភាក្សាជាមួយដៃគូម្ចាស់ជំនួយដើម្បីលើកទឹកចិត្តនិងគាំទ្រកម្ពុជាអាចមានលទ្ធភាពអនុវត្តកម្មវិធីនេះបន្ត និងខិតខំសម្របសម្រួលយ៉ាងណាដើម្បីពង្រីកសេវារណបឱ្យបាន ១ ឬ ២ កន្លែងទៀត (ពិសេសនៅភ្នំពេញ) សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ដោយឱសថមេតាដូន ។
- បានជួបពិភាក្សាការងារជាមួយតំណាងនគរបាលសហពន្ធ័អូស្ត្រាលីនៅកម្ពុជា កាលពីថ្ងៃទី២៧/៧/២០១១ ដោយបានស្នើសុំឱ្យភាគីអូស្ត្រាលីបន្តជួយលើ ការបណ្តុះបណ្តាលជំនាញស៊ើបអង្កេតស្រាវជ្រាវបទល្មើសគ្រឿងញៀន,បណ្តុះបណ្តាលជំនាញវិភាគព័ត៌មានគ្រឿងញៀន, គាំទ្រលើការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀនឱ្យបានស៊ីជម្រៅក្នុងស្រទាប់មហាជនទូទៅ, ការបង្កើតគម្រោងដើម្បីអនុវត្តកម្មវិធីដំណាំជំនួសនៅតំបន់ដែលមានការកាប់បំផ្លាញដើមម្រះព្រៅភ្នំ, ការផ្តល់អាហារូបករណ៍សម្រាប់មន្ត្រីអនុវត្តច្បាប់កម្ពុជា បានទៅសិក្សាជំនាញស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- បានស្នើសុំទៅស្ថានទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅកម្ពុជា តាមរយៈឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីស្នើសុំឱ្យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (Korea International Cooperation Agency .KOICA) ជួយគាំទ្រគម្រោងពង្រឹងសមត្ថភាពស្ថាប័នសម្របសម្រួលកិច្ចការគ្រឿងញៀនថ្នាក់ជាតិ នៅកម្ពុជា (២០១២-២០១៣) ។

➢ ***នៅក្រៅប្រទេស***

អគ្គលេខាធិការដ្ឋាន បានចាត់តាំងមន្ត្រីរបស់ខ្លួន និងសម្របសម្រួលជូនក្រសួង-ស្ថាប័នជាសមាជិក ដើម្បីចាត់មន្ត្រីទៅបំពេញបេសកកម្ម ជាអាទិ៍ :

- ការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ ដោយគណៈប្រតិភូជាន់ខ្ពស់របស់ អ.ជ.ប.គ.ញ នៅសាធារណរដ្ឋប្រជា

ធិបតេយ្យប្រជាមានិតឡាវ ២៤-២៨/៧/២០១១ (សមាសភាពគណៈប្រតិភូ ១០ រូប) ។

- ការចូលរួមវេទិកាលើកទី៥ ស្តីពីការសម្របសម្រួលនឹងទំនាក់ទំនងរបស់កម្មវិធី HAARP (ប្រទេសឡាវ ២៧-២៩/៧/២០១១) ។
- សិក្ខាសាលា ស្តីពីការបង្ការការប្រើបំពានគ្រឿងញៀន "គម្រោង UNODC. H15" ប្រទេសវៀតណាម ៥-៨/៧/ ២០១១ ។
- កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ឡាវ តាមរយៈកិច្ចប្រជុំរវាងស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង ជាមួយស្នងការដ្ឋាននគរបាលខេត្តចំប៉ាសាក់ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ធ្វើនៅស្នងការដ្ឋាននគរបាល ខេត្តព្រះវិហារ ថ្ងៃទី០៧/៧/២០១១) ។
- កិច្ចសហប្រតិបត្តិការ ទ្វេភាគី កម្ពុជា-វៀតណាម តាមរយៈកិច្ចប្រជុំរវាងស្នងការដ្ឋាននគរបាលខេត្តកណ្តាល ជាមួយស្នងការដ្ឋាននគរបាលខេត្តអាងយ៉ាង ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន និងកិច្ចសហប្រតិបត្តិការរវាងការិយាល័យ BLO ខេត្តកណ្តាល ជាមួយការិយាល័យ BLO ខេត្តអាងយ៉ាង (ធ្វើនៅខេត្តកណ្តាល, ថ្ងៃទី១៣/៧/២០១១) ។
- ការស្នើសុំបញ្ចូលគម្រោងស្នើសុំហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងសម្រាប់គម្រោងស្តីពី "ការពង្រឹងសមត្ថភាពស្ថាប័នសម្របសម្រួលកិច្ចការងារត្រួតពិនិត្យគ្រឿងញៀនថ្នាក់ជាតិ" ទៅរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការកូរ៉េ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ក្នុងខែកក្កដាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការចូលរួមពីក្រសួង-ស្ថាប័នរដ្ឋ, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ព្រមទាំង អង្គការជាតិ-អន្តរជាតិពាក់ពន្ធ័នានា បានធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន កាន់តែបានទូលំទូលាយនិងស៊ីជម្រៅក្នុងស្រទាប់មហាជនគ្រប់មូលដ្ឋាន ។ ទន្ទឹមនឹងការងារផ្សព្វផ្សាយអប់រំនេះ យើងបានបង្កើនកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ជាពិសេសកិច្ចប្រតិបត្តិការក្នុងការទប់ស្កាត់ការហូរចូលគ្រឿងញៀនពីតំបន់ព្រំដែន ធ្វើឱ្យបទល្មើសគ្រឿងញៀននៅក្នុងខែកក្កដានេះ មានការថយចុះប្រមាណ២០%បើប្រៀបធៀបនឹងខែមិថុនាកន្លងទៅ ។ យើងក៏បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ជាបន្តបន្ទាប់ ធ្វើឱ្យសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់មានការរីកចម្រើនគួរកត់សំគាល់ ។ ប៉ុន្តែទោះបីជាយើងបានខិតខំពង្រឹងសមត្ថភាព ដល់មន្ត្រីរបស់យើងយ៉ាងណាក៏ដោយ អាស្រ័យដោយការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យារបស់ពួកឧក្រិដ្ឋជនគ្រឿងញៀន បានធ្វើឱ្យមន្ត្រីអនុវត្តច្បាប់របស់យើងនៅតែជួបប្រទះល្បិចកលនិងវិធីសាស្ត្រថ្មីៗជាច្រើនទៀត ដែលនាំឱ្យលទ្ធផលខាងលើ នៅតែមិនទាន់អាចឆ្លើយតបបានសមស្រប និងដើរទាន់ការវិវឌ្ឍន៍នៃបញ្ហាគ្រឿងញៀននាពេលបច្ចុប្បន្ន ។ បញ្ហានេះ ទាមទារការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់នូវមធ្យោបាយ សម្ភារៈបច្ចេកទេស ការផ្លាស់ប្តូរបទពិសោធន៍ និងការបណ្តុះបណ្តាលសមត្ថភាព ដល់មន្ត្រីអនុវត្តច្បាប់បន្ថែមទៀត ។ ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន យើងបានយកចិត្តទុកដាក់ក្នុងការផ្តល់របបផ្គត់ផ្គង់ជាប្រចាំដល់អ្នកញៀនគ្រឿងញៀន និងបានពង្រឹងលើសេវាព្យាបាលថែទាំសុខភាព ធ្វើឱ្យការងារព្យាបាលទទួលបាន នូវគុណភាព និងប្រសិទ្ធភាព

ជាងមុន ។

ជារួម ការអនុវត្តន៍យុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ដែលទទួលបានជោគជ័យកន្លងមក គឺមួយផ្នែកធំបានមកពីកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី តាមរយៈគម្រោងនានា ដែលគាំទ្រដោយបណ្តាប្រទេសជាដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ-អន្តរជាតិនានា ។ ប៉ុន្តែដោយសារការជះឥទ្ធិពលអាក្រក់ពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក តាំងពីឆ្នាំ២០០៩ បានក្លាយជាឧបសគ្គសម្រាប់កម្ពុជាក្នុងការស្វែងរកដៃគូអភិវឌ្ឍន៍នានាបន្ថែមទៀត ហើយគម្រោងមួយចំនួនដែលមានស្រាប់ជាមួយកម្ពុជាក៏មានដំណើរការរអាក់រអួលផងដែរ ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១១

ដើម្បីឈានទៅសម្រេចទិសដៅពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម :

១. **ការកាត់បន្ថយតម្រូវការគ្រឿងញៀន**

១.១. អគ្គលេខាធិការដ្ឋាន នឹងបន្តសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ចាម តាមរយៈការស្នើសុំឱ្យចាត់តំណាងចូលរួមផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN ក្រោមប្រធានបទស្តីពីសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅខេត្តកំពង់ចាម ។

១.២. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងជាសមាជិក របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន និងលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ដើម្បីចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើ ហឹង្សា ។

១.៣. ត្រៀមលក្ខណៈចូលរួមនៅក្នុងកម្មវិធីប្រគល់ ទទួល Sticker ផ្សព្វផ្សាយអប់រំពីគ្រឿងញៀន អេដស៍ អំពើជួញដូរមនុស្ស និងជួញដូរអាវុធជាតិផ្ទុះ ពីក្រសួងទេសចរណ៍ នាថ្ងៃទី ១៦-៨-២០១១ ។

២. **ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន**

២.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីពង្រឹងមន្ត្រីអនុវត្តច្បាប់លើការងារស៊ើបអង្កេតស្រាវជ្រាវបទល្មើសគ្រឿងញៀន នៅក្នុងប្រទេស ទាំងករណីធំៗ និងករណីតូចតាច ។

២.២. អគ្គលេខាធិការដ្ឋាន នឹងសម្របសម្រួលជាមួយស្ថាបន័អនុវត្តច្បាប់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អាជ្ញាធរមូលដ្ឋាននៅតាមព្រំដែន ដើម្បីបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាងក្នុងការទប់ស្កាត់ការហូរចូលគ្រឿងញៀន និង សារធាតុគីមីផ្សំ ។

២.៣. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយអង្គការUNODC ចុះទៅធ្វើការអង្កេតពីលទ្ធភាពក្នុងការបង្កើតការិយាល័យទំនាក់ទំនងព្រំដែន(BLO)សមុទ្រ នៅខេត្តកំពតពីថ្ងៃទី១៨-១៩/៨/២០១១។

២.៤. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តតាកែវ ដើម្បីរៀបចំជួសជុលទីតាំងការិយាល័យ BLO ភ្នំដិន ដើម្បីរៀបចំពិធីប្រគល់សម្ភារៈការិយាល័យ BLO ចំនួន ១៦

មុខ នាដើមខែសីហា ឆ្នាំ២០១១ ។

២.៥. អគ្គលេខាធិការដ្ឋាន នឹងបន្តសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យស្តីពីការ នាំចូល នាំចេញ និងប្រើប្រាស់សារធាតុគីមីផ្សំ ។

២.៦. អគ្គលេខាធិការដ្ឋាន ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាពីលទ្ធផលបឋមពាក់ព័ន្ធដំណើរការសិក្សា និងប្រមូលព័ត៌មាន លើការងារត្រួតពិនិត្យនិងគ្រប់គ្រងសារធាតុគីមីផ្សំនៅខេត្តស្វាយរៀង និង ខេត្តកណ្តាល ។

២.៧. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីចូលរួមរៀបចំយន្តការដោះស្រាយបញ្ហាគ្រឿងញៀននៅបណ្តាខេត្តព្រំដែន កម្ពុជា-ឡាវ ។

## ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជំរុញការស្នើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.២. អគ្គលេខាធិការដ្ឋាន នឹងចាត់មន្ត្រីជំនាញចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការឆ្លើយតបដៃគូសហគមន៍ ដើម្បីប្រជាជនប្រឈមមុខខ្ពស់ នៅថ្ងៃទី០៤-០៥/៨/២០១១ នៅសណ្ឋាគារ ខ្សាច់មាស ខេត្តព្រះសីហនុ ។

៣.៣. អគ្គលេខាធិការដ្ឋាន ត្រៀមសហការការងារជាមួយស្ថាប័នជាតិប្រឆាំងគ្រឿងញៀននៃប្រទេសម៉ាឡេស៊ីពាក់ព័ន្ធនឹងកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ។

៣.៤. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្នុងការដំឡើងបញ្ជីទីកន្លែងដែលត្រូវរៀបចំឱ្យមានសេវាព្យាបាលនៅតាមសហគមន៍ឱ្យបានឆាប់រហ័ស ។

៣.៥. អគ្គលេខាធិការដ្ឋាន នឹងបន្តធ្វើការសម្របសម្រួលជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីអនុវត្តការផ្តល់សេវាព្យាបាលតាមសហគមន៍ លើគោលដៅ ២០% នៃឃុំ-សង្កាត់គោលដៅ ។

៣.៦. អគ្គលេខាធិការដ្ឋាន នឹងសហការ សម្របសម្រួល ជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការអនុវត្តន៍កម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ដោយប្រើប្រាស់ឱសថមេតាដូន ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

៤.១. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយអង្គការ UNODC ក្រោមគម្រោង PATROL ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលដោយផ្ទាល់សម្រាប់មន្ត្រីអនុវត្តច្បាប់ដែលជាសមាជិកការិយាល័យ BLO អំពីបញ្ហាគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែន នៅថ្ងៃទី២៤-២៦/៨/២០១១ នៅខេត្តព្រះសីហនុ ។

៤.២. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានាក្នុងការ រៀបចំគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តព្រំដែន កម្ពុជា-ឡាវ ។

៤.៣. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយអង្គការដៃគូអភិវឌ្ឍ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីបន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីការអនុវត្តន៍ច្បាប់ត្រួត

ពិនិត្យគ្រឿងញៀននិងការកាត់បន្ថយគ្រោះថ្នាក់ នៅតាមបណ្តាខេត្តមួយចំនួនទៀត ។

៤.៤. អគ្គលេខាធិការដ្ឋាននិងក្រសួងយុត្តិធម៌ នឹងបន្តតាមដានអំពីលទ្ធផលបន្តទៀត ចំពោះសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ស្នើសុំការអនុម័តពីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០១១ ។

៤.៥. អគ្គលេខាធិការដ្ឋាន នឹងត្រៀមរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ អំពីកម្មវិធីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់បណ្តាលពីការប្រើបំពានគ្រឿងញៀន សម្រាប់មន្ត្រីអនុវត្តច្បាប់ ពីថ្ងៃទី ០១-០៥/៨/២០១១ នៅខេត្តព្រះសីហនុ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តតាមដានការស្នើសុំបញ្ចូលគម្រោងស្នើសុំហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង សម្រាប់គម្រោងស្តីពី "ការពង្រឹងសមត្ថភាពស្ថាប័នសម្របសម្រួលកិច្ចការត្រួតពិនិត្យគ្រឿងញៀន ថ្នាក់ជាតិ" ដែលបានដាក់ស្នើទៅរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។

៥.២. អគ្គលេខាធិការដ្ឋាន នឹងត្រៀមចាត់មន្ត្រីចំនួន ២ រូប ទៅចូលរួមក្នុងកិច្ចប្រជុំស្តីពីការធ្វើអង្កេតសង្គម (Social Reserch) នៅទីក្រុងបាងកក ប្រទេសថៃ (០៨-១២/៨/២០១១) ។

ក្រៅពីអនុវត្តទិសដៅសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាន នឹងបន្តអនុវត្តការងារមួយចំនួនទៀត :

- នឹងបន្តជំរុញការរៀបចំផែនការជាតិ ៥ ឆ្នាំ (១០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- នឹងត្រៀមរៀបចំសិក្ខាសាលា ដើម្បីផ្សព្វផ្សាយពីលទ្ធផលនៃការវាយតម្លៃនិងស្វែងរកការគាំទ្រសំដៅពង្រឹងសមត្ថភាពរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។
- នឹងបន្តជំរុញកិច្ចដំណើរការក្នុងការប៉ាន់ប្រមាណអំពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។
- នឹងបន្តជំរុញការរៀបចំគំរូលេខកូដសម្គាល់ ហៅកាត់ថា UIC (Unique Identifier Code) សម្រាប់ការគ្រប់គ្រងអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អជបគញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

# សកម្មភាពការងារដឹកនាំ
# អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

| ល.រ | ខ្លឹមសារ និង គោលដៅ |
|---|---|
| ១ | ការស្នើសុំ និងបានការឯកភាពជាគោលការណ៍ពីសម្តេចនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១ ឲ្យក្រសួងមហាផ្ទៃរៀបចំ និងដឹកនាំគណៈកម្មការចម្រុះ ដើម្បីជួយដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា- ឡាវ |
| ២ | បន្តការដឹកនាំ និងណែនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារសម្រាប់ជនបង្គោល និងបណ្តុះបណ្តាលជនបង្គោលអំពីការងារផ្សព្វផ្សាយអប់រំ |
| ៣ | ការដឹកនាំក្រុមការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទៅចូលរួមក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន |
| ៤ | ការណែនាំឲ្យដំឡើងបញ្ជីទីកន្លែងដែលត្រូវរៀបចំឲ្យមានសេវាព្យាបាលនៅតាមសហគមន៍ ដើម្បីត្រៀមលក្ខណៈធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសម៉ាឡេស៊ី លើការងារព្យាបាលតាមសហគមន៍ ដោយជ្រើសរើសអាទិភាពមកពី ភ្នំពេញ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ |
| ៥ | ការណែនាំឲ្យពិនិត្យលទ្ធភាពបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារព្យាបាលតាមសហគមន៍ ឬ ទៅធ្វើទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី |
| ៦ | ការណែនាំឲ្យក្រុមការងារទិន្នន័យ ឬមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ខិតខំឲ្យបានសម្រេចនូវការប្រមូលទិន្នន័យមួយ ដែលឯកភាពគ្នា |
| ៧ | ការណែនាំឲ្យក្រុមការងារអនុវត្តកម្មវិធីប៉ាន់ប្រមាណពីចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា រៀបចំជាបញ្ជីឬតារាងទិន្នន័យជាក់លាក់មួយ |
| ៨ | ការណែនាំឲ្យរៀបចំលិខិតផ្លូវការ ទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន អេដស៍ និងពេស្យាចារ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងសំណើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន |
| ៩ | ការណែនាំឲ្យតាមដានអំពី កាលបរិច្ឆេទ កម្មវិធី ខ្លឹមសារ នៃដំណើរទស្សនកិច្ចទៅកាន់សាធារណរដ្ឋប្រជាមានិតចិន របស់គណៈប្រតិភូជាន់ខ្ពស់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| ១០ | ការណែនាំឲ្យបន្តការតាមដាន និងជំរុញការស្វែងរកថវិកាគម្រោង សម្រាប់ការងារព្យាបាលតាមសហគមន៍ ដែលបានចុះហត្ថលេខាជាមួយ យូ.អិន.អូ.ឌី.ស៊ី |
| ១១ | ការណែនាំឲ្យរៀបចំកិច្ចប្រជុំមួយ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពន្ធនាគារ ជាមួយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិ ដើម្បីពិភាក្សានិងដោះស្រាយបញ្ហានានា ដែលបង្កការលំបាកដល់សមត្ថកិច្ចពន្ធនាគារ និងសមត្ថកិច្ចអនុវត្តច្បាប់ |
| ១២ | ការណែនាំឲ្យចូលរួមក្នុងវេទិកា ស្វែងយល់ពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ |
| ១៣ | ការណែនាំឲ្យចូលរួមពិនិត្យ និងកែសម្រួលលើខ្លឹមសារសេចក្តីព្រាង គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា របស់ក្រសួងអប់រំយុវជន និងកីឡា |
| ១៤ | ការណែនាំឲ្យចូលរួមប្រជុំពេញអង្គគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាង ឯកសារគោលនយោបាយជាតិ ស្តីពីសន្តិសុខលម្ហសមុទ្រ (១៩/៧/២០១១) |
| ១៥ | ការអនុញ្ញាតជាគោលការណ៍ឲ្យគណៈប្រតិភូជាន់ខ្ពស់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ២៥-២៨/៧/២០១១ |
| ១៦ | ការណែនាំឲ្យចូលរួមក្នុងកិច្ចប្រជុំពិភាក្សាកម្រិតជំនាញ ក្នុងការរៀបចំផែនការចំណូល- ចំណាយថវិកា ឆ្នាំ២០១២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២៩/៧/២០១១) |
| ១៧ | ការណែនាំឲ្យរៀបចំកិច្ចប្រជុំកម្រិតជំនាញ ដើម្បីធ្វើផែនការសកម្មភាពជាតិ ៥ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ១៨/៧/១១ |

## សកម្មភាពផ្សព្វផ្សាយអប់រំ ប្រចាំខែ កក្កដា ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាប័ន | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អ.ជ.ប.គ.ញ | -បានចូលរួមសន្និសីទសារព័ត៌មានស្តីពី មហោស្រពប្រឡងតន្ត្រីសម័យថ្នាក់ជាតិ របស់ស្ថានីយទូរទស្សន៍ជាតិកម្ពុជា ដែលមានបញ្ចូលវិធីសាស្រ្តអប់រំមួយចំនួនពីគ្រឿងញៀន ២៩/៦/២០១១ អ្នកចូលរួម ៦០ នាក់<br>-បានសហការជាមួយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះទៅផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តព្រៃវែង ០៧/៧/២០១១ អ្នកចូលរួម ៤០០ នាក់ និងនៅខេត្តកំពត ២២/៧/២០១១ អ្នកចូលរួម ៣៥០ នាក់ | ៨១០ នាក់ |
| ២ | ភ្នំពេញ | -ផ្តល់បទសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន ស្តីពី ការទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន | |
| ៣ | កំពង់ធំ | -មន្ត្រីអនុវត្តច្បាប់-អាជ្ញាធរស្រុកកំពង់ស្វាយ, ស្រុកស្ទឹងសែន ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ( ៨៣៣ នាក់ / ស្រី ៣០៥ នាក់ )<br>-តំបន់ប្រតិបត្តិការសឹករងខេត្ត ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀនដល់ នាយទាហាន ពលទាហាន ( ១៧៤ នាក់ / ស្រី ៨ នាក់ )<br>-អាជ្ញាធរស្រុកបារាយណ៍ ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ឃុំចំនួន២ មានប្រជាជនចូលរួម ( ២០៧ នាក់ / ស្រី ៧៣ នាក់ ) និងសហការជាមួយអង្គការ ស៊ី.ស៊ី.ដេប ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាជន ( ៥០ នាក់ / ស្រី ១៥ នាក់ )<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់កម្មករនិយោជិក ៥ សហគ្រាស ( ១២៥ នាក់ / ស្រី ៧០ នាក់ ) | ១.៣៨៩ នាក់ |
| ៤ | បាត់ដំបង | -នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោកឃ្មុំ ស្រុកថ្មគោល បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននិងមេរោគអេដស៍ ក្នុងកម្មវិធីផ្សព្វផ្សាយការអនុវត្តន៍ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ( ២៦៦ នាក់ / ស្រី ៥៥ នាក់ )<br>-នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអន្លង់រុន ឃុំជ្រៃ ស្រុកថ្មគោល បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀននិងមេរោគអេដស៍ ក្នុងកម្មវិធីផ្សព្វផ្សាយការអនុវត្តន៍ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ( ១៥៦ នាក់ / ស្រី ១០០ នាក់ ) | ៤២២ នាក់ |
| ៥ | ព្រះវិហារ | -អាជ្ញាធរក្រុងព្រះវិហារ និងស្រុករវៀង ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ( ៩៦ នាក់ / ស្រី ៤៦ នាក់ ) | ៩៦ នាក់ |
| ៦ | ប៉ៃលិន | -លេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន សហការជាមួយ អង្គការ CHED និងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ( ៥១៥ នាក់ ) | ៥១៥ នាក់ |
| ៧ | ក្រចេះ | -នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ( ២០៥ នាក់ / ស្រី ១០៥ នាក់ ) | ២០៥ នាក់ |
| | **សរុប** | | ៣.៤៣៧ នាក់ |

## បទល្មើសគ្រឿងញៀនបង្ក្រាបក្នុងខែ កក្កដា ឆ្នាំ ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ផលិត | | | ចរាចរជួញដូរចែកចាយ | | | ដាំដុះ ចម្រាញ់ប្រែងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **6** | **23** | **6** | 2 | 16 | 6 | 4 | 7 | 0 | | | | | | | | | |
| 2 | អគ្គនាយកដ្ឋានគយ | **1** | **1** | **1** | | | | 1 | 1 | 1 | | | | | | | | | |
| 3 | ន.ប ភ្នំពេញ | **14** | **28** | **2** | | | | 10 | 20 | 2 | | | | 4 | 8 | 0 | | | |
| | ន.ប កំពង់ចាម | **7** | **20** | **4** | | | | 5 | 15 | 2 | | | | 2 | 5 | 2 | | | |
| | ន.ប ក្រចេះ | **5** | **14** | **1** | | | | 5 | 14 | 1 | | | | | | | | | |
| | ន.ប ព្រះសីហនុ | **2** | **2** | **2** | | | | | | | | | | 2 | 2 | 2 | | | |
| | ន.ប សៀមរាប | **5** | **10** | **4** | | | | 4 | 8 | 4 | | | | 1 | 2 | 0 | | | |
| | ន.ប ព្រះវិហារ | **1** | **0** | **0** | | | | | | | 1 | 0 | 0 | | | | | | |
| | ន.ប ប៉ៃលិន | **1** | **7** | **2** | | | | 1 | 7 | 2 | | | | | | | | | |
| | ន.ប បាត់ដំបង | **2** | **6** | **2** | | | | 2 | 6 | 2 | | | | | | | | | |
| | ន.ប បន្ទាយមានជ័យ | **13** | **25** | **7** | | | | 12 | 24 | 7 | | | | 1 | 1 | 0 | | | |
| | ន.ប ឧត្តរមានជ័យ | **0** | **3** | **0** | | | | | | | | | | | | | 0 | 3 | 0 |
| | ន.ប ស្ទឹងត្រែង | **1** | **2** | **1** | | | | 1 | 1 | 1 | | | | | | | 0 | 1 | 0 |
| | ន.ប កោះកុង | **1** | **2** | **2** | | | | 1 | 2 | 2 | | | | | | | | | |
| | ន.ប រតនគិរី | **3** | **5** | **1** | | | | 3 | 5 | 1 | | | | | | | | | |
| | **សរុប** | **62** | **148** | **35** | **2** | 16 | 6 | **49** | 110 | 25 | **1** | 0 | 0 | **10** | 18 | 4 | **0** | 4 | 0 |

## វត្ថុតាងចាប់យក ប្រចាំខែ កក្កដា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ***WY*** (គ្រាប់) | ***ICE*** (ក្រាម) | ***Heroine*** (ក្រាម) | ដើមកញ្ឆា ម² | កញ្ឆាក្រៀម (ក្រាម) | ***Ecstasy*** (គ្រាប់) | ***Pseudo-Ephedrine*** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| ***1*** | មន្ទីរប្រឆាំងគ្រឿងញៀន | *1.591* | *350,90* | | | ក្រៀម *222,40*<br>ជរ *241,80* | | | *297,30* | |
| ***2*** | អគ្គនាយកដ្ឋានគយ រដ្ឋាករ | | | | | ជរ *7.897* | | | | |
| ***3*** | ន.ប ភ្នំពេញ | *46 ½* | *4,72* | | | | | | | |
| ***4*** | ន.ប កំពង់ចាម | *6* | *9,24* | | | | | | | |
| ***5*** | ន.ប ព្រះសីហនុ | *½* | *0,08* | | | | | | | |
| ***6*** | ន.ប សៀមរាប | *1* | *2,52* | | | | | | | |
| ***7*** | ន.ប ស្ទឹងត្រែង | *10* | | | | | | | | |
| ***8*** | ន.ប ព្រះវិហារ | | | | *11 ដើម* | | | | | |
| ***9*** | ន.ប រតនគីរី | *28* | | | | | | | | |
| ***10*** | ន.ប បាត់ដំបង | *3 ½* | | | | | | | | |
| ***11*** | កោះកុង | *51* | | | | | | | | |
| ***12*** | ន.ប បន្ទាយមានជ័យ | *117* | *12,60* | | | | | | | |
| ***13*** | ន.ប ក្រចេះ | | *11,10* | | | | | | | |
| ***14*** | ន.ប ប៉ៃលិន | *570* | *171,15* | | | | | | | |
| | សរុប | ***2.424 ½*** | ***562,31*** | | ***11 ដើម*** | ជរ *8.138,80*<br>ក្រៀម *222,40* | | | ***297,30*** | |

**វត្ថុតាងផ្សេងៗ ៖**

-មន្ទីរប្រឆាំង គ្រ.ញ *WY* ៩៥,៩០ ក្រាម, មេតំហ្វេតាមីនរាវ២០៩,៩០ ក្រាម, អ៊ិចស្តាស៊ី ៦៥,៨០ ក្រាម, សារធាតុគីមីផ្សំគ្រឿងញៀន ១.៤៣៩,៤០ ក្រាម, ពុម្ព៧, ជញ្ជីង៣, ដង្កៀ១, ម៉ាស៊ីនក្រឡុកថ្នាំ១, រថយន្ត១, ម៉ូតូ៥, លុយ ១.១០០ ដុល្លារ, ឧបករណ៍

| | |
|---|---|
| | ផលិត-វេចខ្ចប់មួយចំនួន |
| -អគ្គនាយកដ្ឋានគយ រដ្ឋាករ | លុយ ៤៦០ ដុល្លារ, ២.៥០០ រូពីឥណ្ឌា |
| -ន.ប ភ្នំពេញ | ម្សៅ ស ១១,០៩ ក្រាម, ជញ្ជីង៣, ម៉ូតូ៣, លុយ ២០៦.៥០០ រៀល, ៥៥ ដុល្លារ |
| -ន.ប កំពង់ចាម | ឧបករណ៍ប្រើប្រាស់មួយចំនួន |
| -ន.ប ព្រះសីហនុ | ម៉ូតូ១គ្រឿង, ឧបករណ៍ប្រើប្រាស់មួយចំនួន |
| -ន.ប សៀមរាប | ម៉ូតូ១, លុយ ៤៥០.០០០ រៀល, ១០ ដុល្លារ, ឧបករណ៍ប្រើប្រាស់មួយចំនួន |
| -ន.ប បន្ទាយមានជ័យ | រថយន្ត១, ម៉ូតូ ២ គ្រឿង |
| -ន.ប ក្រចេះ | កាំភ្លើងខ្លី១ |
| -ន.ប ប៉ៃលិន | ម៉ូតូ ៣, ជញ្ជីង ២ |

## ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូលក្នុង ប្រចាំខែ កក្កដា ឆ្នាំ ២០១១

| *ឈ្មោះសារធាតុគីមី* | *អាជ្ញាបណ្ណ័ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល* | | | *អាជ្ញាបណ្ណ័ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* | | | *សរុប* | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Glacial Acetic Acide | | | | 175.000 | | | 175.000 | | |
| Sodium Hypochloride | | | | 54.000 | | | 54.000 | | |
| Formic Acid | 45.000 | | | | | | 45.000 | | |
| Sodium Sulfate | | | | 3.024.000 | | | 3.024.000 | | |
| Thinner | | | | 20.000 | | | 20.000 | | |
| Acide Acetic | | | | 123.900 | | | 123.900 | | |
| Calcium Carbonate | | | | 65.000 | | | 65.000 | | |
| Soda Ash | | | | 1.045.333 | | | 1.045.333 | | |
| Ethyl Acetate | | | | 3.000 | | | 3.000 | | |
| Formic Acid | | | | 50.000 | | | 50.000 | | |
| Acetone | | | | 29.000 | | | 29.000 | | |
| Methylene Chloride | | | | 54.000 | | | 54.000 | | |
| Methyl Ethyl Ketone | | | | 20.000 | | | 20.000 | | |
| Toluene | | | | 25.850 | | | 25.850 | | |
| Solvent | | | | 10.000 | | | 10.000 | | |
| Caustic Soda | | | | 301.000 | | | 301.000 | | |
| Total : | 45.000 | | | 5.000.083 | | | 5.045.083 | | |